# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៣  ខែ វិច្ឆិកា  ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ១០០,៩៧៣ ដុល្លារអាមេរិក សម្រាប់

## គម្រោងកែលម្អប្រព័ន្ធលូ និងផ្លូវ ក្នុងឃុំសង្កែពីរ ស្រុកឆែប ខេត្តព្រះវិហារ



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន (ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយ តូច សន្តិសុខ មនុស្សជាតិ ជំនួយ គូសាណូណិ) រដ្ឋាភិបាលជប៉ុន បានផ្តល់ទឹកប្រាក់សរុប ចំនួន១០០,៩៧៣ដុល្លាអាមេរិកដល់មន្ទីរសារធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ សម្រាប់គម្រោងកែលម្អប្រព័ន្ធលូ និងផ្លូវ ក្នុងឃុំសង្កែពីរ ស្រុកឆែប ខេត្តព្រះវិហារ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក សំ លាងទ្រី ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ នៅស្ថានទូតជប៉ុន។ ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ក៏បានអញ្ជើញចូលរួមជាសាក្សីក្នុងពិធីនេះផងដែរ។

ជំនួយឥតសំណង សម្រាប់គម្រោងកែលម្អប្រព័ន្ធលូ និងផ្លូវក្នុងឃុំសង្កែពីរ នឹងត្រូវបានស្ថាបនាដោយប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ។ គម្រោងនេះ រួមមានការសាងសង់ប្រព័ន្ធលូចំនួន២ និងការស្ថាបនាផ្លូវគ្រោះក្រហមប្រវែង៤,០០០ម៉ែត្រ។ យើងសង្ឃឹមថាគម្រោងនេះ នឹងជួយកាត់បន្ថយការខូចខាតដោយសារទឹកជំនន់ជារៀងរាល់





ឆ្នាំ និងជួយសម្រួលដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា សាលារៀន មណ្ឌលសុខភាព និងផ្សារដល់ប្រជាពលរដ្ឋក្នុងឃុំ។ ដោយមានជំនួយផ្នែកបច្ចេកទេសពីមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ សហគមន៍នឹងថែទាំនូវគ្រឿងបរិក្ខារផ្សេងៗ និងផ្លូវអោយមានលក្ខណៈល្អប្រសើរ។

ជំនួយ *គូសាណូណិ* របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្ថាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥១.៩លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៥១៨ គម្រោងនៅទូទាំងប្រទេស។




*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ័៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*